# សេចក្តីប្រកាសអំពីអត្ថប្រយោជន៍សមាជិក Health Net ថ្មី៖ **សេវាអ្នកជំនាញខាងសម្រាលកូន**

**ផ្តល់ជូនអ្នកនូវការថែទាំ និងការគាំពារផ្ទាល់ខ្លួនរបស់អ្នកក្នុងអំឡុងពេលមានផ្ទៃពោះ**



## តើអ្វីទៅជាអ្នកជំនាញខាងសម្រាលកូន?

អ្នកជំនាញខាងសម្រាលកូនគឺជាបុគ្គលិកផ្នែកសម្រាលកូនដែលជួយអ្នកអំឡុងពេលមានផ្ទៃពោះ ពេលសម្រាលកូន និងក្រោយពេលសម្រាលកូន (ពេលសម្រាលកូនរួច)។ អ្នកជំនាញខាងសម្រាលកូននៅរង់ចាំជួយអ្នកដោយផ្ទាល់ ឬតាមអនឡាញ។ ការថែទាំដែលពួកគាត់ផ្តល់ឱ្យអាចធ្វើឡើងក្នុងអំឡុងពេលទៅជួបពិគ្រោះនៅការិយាល័យអ្នកផ្តល់សេវា ឬនៅក្នុង៖

- មន្ទីរពេទ្យ
- មជ្ឈមណ្ឌលជំនាញខាងសម្រាលកូន
- ផ្ទះរបស់អ្នក

អ្នកជំនាញខាងសម្រាលកូនផ្តល់ការថែទាំដែលជួយដល់អ្នកសម្រាលកូនដែលមានប្រវត្តិ និងវប្បធម៌ចម្រុះ។ ពួកគាត់ផ្តល់ជំនួយ ដើម្បីឱ្យមានពេលវេលាប្រកបដោយក្តីសង្ឃឹមកាន់តែច្រើនអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល។ អ្នកជំនាញខាងសម្រាលកូនក៏អាចជួយធ្វើឱ្យប្រសើរឡើងចំពោះលទ្ធផលសុខភាពចំពោះមាតាបិតាដែលសម្រាលកូន និងកូនៗរបស់ពួកគាត់ផងដែរ។

## *របៀបដែលអ្នកជំនាញខាងសម្រាលកូនអាចជួយអ្នកបាន*

អ្នកជំនាញខាងសម្រាលកូនជួយទៅតាមតម្រូវការផ្សេងៗជាច្រើនរបស់អ្នកមានផ្ទៃពោះ និងអ្នកដែលសម្រាលកូនរួច។ ពួកគាត់អ្នកជួយអ្នក៖

- កំណត់ និងសរសេរអំពីផែនការសម្រាលកូន។
- ស្វែងយល់អំពីការមានផ្ទៃពោះ និងក្រោយពេលសម្រាលកូន។
- គ្រប់គ្រងការថែទាំរបស់អ្នកតាមរយៈប្រព័ន្ធថែទាំសុខភាព។
- ភ្ជាប់ជាមួយធនធានសហគមន៍។
- ផ្តល់ជំនួយអំឡុងពេលឈឺពោះឆ្លងសម្រាលកូន ពេលកំពុងសម្រាលកូន និងក្រោយសម្រាលកូនរួច។
- សម្របខ្លួនទៅនឹងការបំបៅកូនដោយទឹកដោះម្តាយ និងផ្តល់ការគាំពារ។

(បន្ត)

## *អ្វីដែលអ្នកអាចរំពឹងទាក់ទងនឹងអត្ថប្រយោជន៍អ្នកជំនាញខាងសម្រាលកូនរបស់អ្នក*



- សូមជួបពិគ្រោះជាមួយអ្នកជំនាញខាងសម្រាលកូនម្តង ដើម្បីស្គាល់គ្នាទៅវិញទៅមក។
- ការជួបពិគ្រោះអាចមានរហូតដល់ទៅប្រាំបីដងបន្ថែមទៀតក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាលកូន។
- ជួយពេលឈឺពោះសម្រាលកូន និងពេលកំពុងសម្រាលកូន។ (ករណីនេះក៏នឹងអនុវត្តទៅលើការសម្រាលកូនដែលមិនអាចកើតបានហើយស្លាប់ក្នុងផ្ទៃ។ ឬសម្រាប់ដំណើរការរលូតកូនតាមធម្មជាតិ ឬការរំលូតកូនដោយចេតនា។ )
- ការជួបពិគ្រោះក្រោយសម្រាលកូនរហូតដល់ពីរដងរយៈពេល បីម៉ោងបន្ទាប់ពីបញ្ចប់ការមានផ្ទៃពោះ។

## *របៀបដែលអ្នកអាចទទួលបានអ្នកជំនាញខាងសម្រាលកូន*

អ្នកត្រូវការទម្រង់បែបបទជាលាយលក្ខណ៍អក្សរដែលបំពេញដោយអ្នកផ្តល់សេវារបស់អ្នក។ ករណីនេះអាចជាវេជ្ជបណ្ឌិត ឬបុគ្គលិកជំនាញដែលមានអាជ្ញាបណ្ណផ្សេងទៀតខាងផ្នែកព្យាបាលដែលបំពេញការងារក្នុងវិសាលភាពនៃវិជ្ជាជីវៈរបស់ពួកគេ។ **អ្នកផ្តល់សេវាមិនចាំបាច់ចុះឈ្មោះក្នុង Medi-Cal ទេ។ ហើយពួកគេក៏មិនចាំបាច់ជាអ្នកផ្តល់ក្នុងបណ្តាញដែរ។**

បំពេញជំហានមួយក្នុងចំណោមជំហានខាងក្រោម ដើម្បីស្វែងយល់បន្ថែមអំពីសេវាអ្នកជំនាញខាងសម្រាលកូន៖

1. ទូរសព្ទទៅ Health Net តាមរយៈលេខ **800-675-6110 (TTY 711)**, 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។
2. ទូរសព្ទទៅជម្រើសថែទាំសុខភាព Medi-Cal របស់រដ្ឋតាមលេខ **800-430-4263 (TTY 800-430-7077)**។
3. សាកសួរគ្រូពេទ្យ ឬគ្លីនិករបស់អ្នកអំពីអត្ថប្រយោជន៍នេះ។

Health Net, 21281 Burbank Blvd.,Woodland Hills, CA 91367

Health Net Community Solutions, Inc. គឺជាបុត្រសម្ព័ន្ធមួយរបស់ Health Net, LLC.។ Health Net គឺជាសញ្ញាសម្គាល់ពាណិជ្ជកម្មដែលបានចុះបញ្ជីរបស់ Health Net, LLC.។ រក្សាសិទ្ធិគ្រប់យ៉ាង។

FLY061737DP00 (5/23)